**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
~~~~~x~~~~~

**ក្រសួងពាណិជ្ជកម្ម**
**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**
~~~~x~~~~

# របាយការណ៍
# បូកសរុបការងារ ប្រចាំឆ្នាំ ២០០៨
# និង
# ទិសដៅការងារឆ្នាំ ២០០៩

~~*~~

ដោយការខិតខំព្យាយាមក្នុងការងាររបស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការទាំងអស់ក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញា និង ដោយមានការជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មទាំងផ្នែកស្មារតី និង សំភារៈ រួមទាំងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធិជាមួយនឹងស្ថាប័នជាតិ- អន្តរជាតិ នានាផងនោះ ធ្វើអោយដំណើរការ កែលំអរ និង លើកកំពស់ ការអនុវត្តវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជា កាន់តែមានភាពរឹងមាំ និង ល្អប្រសើរឡើង ពីមួយថ្ងៃទៅមួយ ថ្ងៃដែលជាការរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ សកម្មភាពជាក់ស្តែងក្នុងឆ្នាំ ២០០៨ នេះ របស់នាយកដ្ឋានទទួលបាន លទ្ធផលមួយចំនួនដូចខាងក្រោមៈ

## I. <u>លទ្ធផលដែលទទួលបាន</u>

### ក-<u>ការងាររៀបចំច្បាប់ និង បទបញ្ញត្តិនានា</u> :

### A- ១. ផ្នែកច្បាប់

#### ១-១ ការងារតាក់តែងច្បាប់

-បាន នឹង កំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ការសំគាល់ភូមិសាស្ត្រទំនិញ(Law on Geographical Indications) និង ការអនុវត្តន៍គំរោងសាកល្បងលើកដំបូង លើផលិតផលសំគាល់ភូមិសាស្ត្រនៅកម្ពុជា ដោយមាន ជំនួយឧបត្ថម្ភពី

សហគមន៍អឺរ៉ុប និង រដ្ឋាភិបាលបារាំង។ បច្ចុប្បន្នពង្រាងច្បាប់នេះ កំពុងត្រូវបានពិនិត្យ និងកែសំរួលដើម្បីស្វែងរកចំណុចជាវិជ្ជមាន និង អវិជ្ជមានក្នុងផលប្រយោជន៍ជាតិ និង ផ្អែកតាមកិច្ចព្រមព្រៀង TRIPS ហើយសង្ឃឹមថាពង្រាងច្បាប់នេះនឹងដាក់ជូនគណៈរដ្ឋមន្ត្រីក្នុងពេលឆាប់ៗនេះ ។

-បាន និង កំពុងរៀបចំ សេចក្តីព្រាងច្បាប់ស្តីពី ព័ត៌មានសំងាត់ និង ការសំងាត់ពាណិជ្ជកម្ម និង អជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ (Draft Law on Trade Secrets and Undisclosed Information and Compulsory Licensing for Public Health) រួមទាំងធ្វើការផ្លាស់ប្តូរការយល់ឃើញ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ។

## ១-២ ការបកប្រែច្បាប់ និងសន្ធិសញ្ញាផ្សេងៗ

-បានបញ្ចប់ការបកប្រែអនុស្សារណៈ នៃការយោគយល់គ្នារវាងរដ្ឋាភិបាល នៃរដ្ឋជាសមាជិកសមាគមប្រជាជាតិ អាស៊ីអាគ្នេយ៍ និង រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកម្មសិទ្ធិបញ្ញា ពីភាសាអង់គ្លេស និង ភាសាខ្មែរ។

- បានបញ្ចប់ការបកប្រែកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរី រវាង អាស៊ាន អូស្ត្រាលី និងណូវែហ្សេឡង់ (AANZFTA) ពីភាសាអង់គ្លេសមកជាភាសាខ្មែរ។

- បានបកប្រែអនុក្រឹត្យគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ទៅជាភាសារអង់គ្លេស ដើម្បីផ្សព្វផ្សាយទៅបរទេស។

-បានបញ្ចប់ការបកប្រែ និង ព្រៀងប្រកាសស្តីពី ភ្នាក់ងារចុះបញ្ជីម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងកំពុងកែសម្រួល ហើយសង្ឃឹមថា ប្រកាសនេះនឹងត្រូវដាក់អោយប្រើប្រាស់នៅក្នុងឆ្នាំ ២០០៩ ខាងមុខ ។

-បានបញ្ចប់ការបកប្រែសេចក្តីព្រាងច្បាប់ស្តីពី ការសំគាល់ភូមិសាស្ត្រទំនិញ និងអនុក្រឹត្យ ស្តីពី ការអនុវត្តន៍ច្បាប់ការសំគាល់ភូមិសាស្ត្រទំនិញ ក្រោមជំនួយបច្ចេកទេសពីទីភ្នាក់បារាំងដើម្បីការអភិវឌ្ឍន៍ (AFD) ។

-បានបកប្រែពង្រាងអនុក្រឹត្យស្តីពី ការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួមពីភាសាខ្មែរ ទៅជាអង់គ្លេស។

-កំពុងបញ្ចប់ការបកប្រែ **Trademark Manual, PCT, TRIPs** និងកំពុងកែសម្រួលផ្នែកខ្លះនៃ **Trademark Manual** ដើម្បីអោយងាយស្រួលក្នុងការអនុវត្តន៍។

-កំពុងធ្វើការបកប្រែសៀវភៅ របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ស្តីពីការអនុវត្តច្បាប់ម៉ាក ពីភាសាអង់គ្លេសទៅជាភាសាខ្មែរ។

## ១-៣ ការសិក្សា និង ចងក្រងច្បាប់ និង សន្ធិសញ្ញាផ្សេងៗ

-ក្រុមការងារផ្នែកច្បាប់កំពុងធ្វើការសិក្សាទៅលើសេចក្តីព្រាងច្បាប់ស្តីពី ព័ត៌មានសំងាត់ និងការសម្ងាត់ ពាណិជ្ជកម្ម និង ច្បាប់ស្តីពីអជ្ញាប័ណ្ណបញ្ជាសម្រាប់សុខភាពសាធារណៈ ដើម្បីរកអោយឃើញផលប្រយោជន៍ និង គុណវិបត្តិរបស់វា ចំពោះជាតិ រួមទាំងបទពិសោធន៍ដែលប្រទេសកំពុងអភិវឌ្ឍន៍បានអនុវត្តន៍ និង លទ្ធផល។

-បានរៀបចំចងក្រងច្បាប់ អនុសញ្ញា និង កិច្ចព្រមព្រៀងមួយចំនួន ដូចជា TRIPS, Vienna Classification, Nice Classification , Locarno Classification អោយមានទំរង់ជា Soft Copy និង Hard Copy ។

-បានសិក្សាលើច្បាប់ទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា។

-សិក្សាច្បាប់ OPTICAL DISK និង COLLECTIVE MANAGEMENT ។

-សិក្សា និងផ្តល់យោបល់ទៅលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន អឺរ៉ុប លើវិស័យកម្មសិទ្ធិបញ្ញា។

## ២. ផ្នែកចំណេះដឹងសាធារណះ

### ២-១ រៀបចំកិច្ចប្រជុំ និង សិក្ខាសាលាផ្សេងៗក្នុងស្រុក

ស្របតាមបេសកម្ម និង ផែនការ របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ការិយាល័យសហប្រតិបត្តិការ និង កិច្ចការច្បាប់បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការផ្សព្វផ្សាយ និង ការពង្រឹងការការពារកម្មសិទ្ធិបញ្ញា នៅតាមស្រទាប់សិស្ស និស្សិត ប្រជាជន ក៏ដូចជា អាជីវករទាំងអស់ ដើម្បីអោយពួកគេកាន់តែមានការយល់ដឹងស៊ីជុំរៅពីកម្មសិទ្ធិបញ្ញា និងចូលរួមលើកស្ទួយការការពារកម្មសិទ្ធិបញ្ញា ដែលមានសកម្មភាពដូចខាងក្រោមះ

| | | |
|---|---|---|
| - បានធ្វើសិក្ខាសាលាក្នុងប្រទេសចំនួន : | ០៨ | លើក |
| - សរុបសិក្ខាកាម ជាមន្ត្រីរាជការ: | ៦៣ | នាក់ព្រមទាំងមានការចូលរួមពីនិស្សិតជាច្រើននាក់ ។ |
| - ក្នុងនោះ : -មន្ត្រីនាយកដ្ឋានចំនួន : | ១៨ | នាក់ |
| -មន្ត្រីអង្គភាពពាក់ព័ន្ធចំនួនះ | ៤៥ | នាក់ |
| -ជនបរទេសចំនួន | 0 | នាក់ |

### ២-២- បញ្ជូនបេក្ខជនទៅចូលរួមសិក្ខាសាលា និងកិច្ចប្រជុំក្រៅស្រុក

នៅក្នុងឆ្នាំ ២០០៨ នាយកដ្ឋាន បានរៀបចំបែបបទ ដើម្បីបញ្ជូនមន្ត្រី និងថ្នាក់ដឹកនាំនាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួង និងស្ថាប័នពាក់ព័ន្ធ ចូលរួមសិក្សាមុខ ជំនាញ កម្មសិទ្ធិបញ្ញា ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាក្រៅប្រទេស

| | | |
|---|---|---|
| - សរុបចំនួនសិក្ខាសាលា ដែលបានចូលរួម : | ២៦ | លើក |
| - សរុបសិក្ខាកាម ដែលបានចូលរួម : | ៤៩ | នាក់ |
| - ក្នុងនោះ : -មន្ត្រីនាយកដ្ឋានចំនួន : | ២៦ | នាក់ |
| -មន្ត្រីអង្គភាពពាក់ព័ន្ធចំនួនះ | ២៣ | នាក់ |

### ២-៣ ចូលរួមឧទ្ទេសនាមជំនាញកម្មសិទ្ធិបញ្ញាក្នុងប្រទេស :

នាយកដ្ឋានកម្មសិទ្ធិបញ្ញា បានចូលរួមយ៉ាងសកម្មក្នុងបទបង្ហាញ អំពីជំនាញកម្មសិទ្ធិបញ្ញា :

| | | |
|---|---|---|
| - សរុបចំនួនឧទ្ទេសនាម : | ០៦ | លើក |

- សរុបចំនួនសិក្ខាកាម ចូលរួម : ៦៣ នាក់

## ៣. ផ្នែកសហប្រតិបត្តិការ

- បាន និងកំពុងពិនិត្យផ្តល់មតិលើ WHO Framework Convention on Tobacco Control ។

- រៀបចំ សិទ្ធិប្រទានសំរាប់ចុះហត្ថលេខាលើអនុសារណៈយោគយល់គ្នារវាង អាស៊ាន-ចិន លើវិស័យកម្មសិទ្ធិបញ្ញា ។

-នាយកដ្ឋានបានសហការជាមួយ **Mr. Tom Pengelly** ក្នុងកំឡុងទស្សនៈកិច្ច ចាប់ពីថ្ងៃទី ០៣ ដល់ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៨ ដើម្បីរៀបចំផែនការសកម្មភាពកម្មវិធី ECAP III ។

-រៀបចំផែនការ និង គំរោងថវិកា សំរាប់ធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំក្រុមការងារអាស៊ានផ្នែកកម្មសិទ្ធិបញ្ញា (AWGIPC) លើកទី ៣១ នៅ ឆ្នាំ ២០០៩ តាមសំណើរបស់អគ្គនាយក ការិយាល័យសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា ប្រទេសម៉ាឡេស៊ី តាមរយៈ លិខិតលេខ MyIPO/T-O. 94/2/2 Klt3 ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៨ ។

-រៀបចំលិខិតផ្ញើជូនអគ្គនាយកអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីចាត់បញ្ជូនជំនាញការមកផ្តល់ការហ្វឹកហ្វឺន លើការត្រួតពិនិត្យម៉ាកជារូបភាព និងធ្វើអោយប្រសើរឡើងនូវប្រព័ន្ធ IPAS ។

-បានធ្វើរបាយការណ៍ចុះបញ្ជីម៉ាក ប្រកាសនីយបត្រតក្កកម្ម គំនូសឧស្សាហកម្ម និងការការពារពូជថ្មីនៃដំណាំ ចាប់ពីឆ្នាំ ២០០២- ២០០៧ ជូន ECAP II ។

-បំពេញសំណួរ (Questionnaires) របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ស្តីពី ម៉ាក ប្រកាសនីយបត្រតក្កកម្ម និង គំនូសឧស្សាហកម្ម ។

-បានចងក្រង ព័ត៌មាន សេវាសាធារណៈនៃកម្មសិទ្ធិបញ្ញា ដែលពាក់ព័ន្ធ និងចង្កោមសេវាទី ៤ ក្នុងគោលនយោបាយ ស្តីពី ការផ្តល់សេវាសាធារណៈនៅកម្ពុជា ។

-ចូលរួមកិច្ចប្រជុំដើម្បីពិនិត្យពង្រាងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និង គូវ៉ែត ក្រោមអធិបតីភាព របស់ **ឯកឧត្តម គឹម ស៊ីថន** នៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨ នៅក្រសួងពាណិជ្ជកម្ម ។

-ចូលរួមធ្វើការចរចារជាមួយភាគីរុស្សី ស្តីពី ការបើកច្រកទីផ្សារ និងវិធានប្រភពដើមទំនិញ នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៨ នៅក្រសួងពាណិជ្ជកម្ម ។

-ចូលរួមប្រជុំ ស្តីពី ពិនិត្យ និងសម្រេច Log Framework ជាមួយមន្ត្រីដែលជាសមាជិកសរសរស្តម្ភទី ១ នៃ អភិក្រម គ្របដណ្តប់វិស័យពាណិជ្ជកម្ម (Trade Swap) និងដៃគូរអភិវឌ្ឍន៍ នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៨ នៅក្រសួងពាណិជ្ជកម្ម ។

-ចូលរួមប្រជុំក្នុងកិច្ចពិភាក្សាការងារ នៃក្រុមប្រឹក្សាចម្រុះ កម្ពុជា-អាមេរិក ស្តីពី ពាណិជ្ជកម្ម និងការវិនិយោគ នៅថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០០៨ នៅក្រសួងពាណិជ្ជកម្ម ។

-ស្នើសុំគោលការណ៏អន្តរាគមន៏កំណត់ទូត ទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំទិដ្ឋាការពីស្ថានទូតអូស្ត្រាលី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ជូនមន្ត្រីជាន់ខ្ពស់ ដើម្បីចូលរួមកិច្ចប្រជុំស្តីពី គណៈកម្មការពិភាក្សាពាណិជ្ជកម្ម អាស៊ី អូស្ត្រាលី ណូវែហ្សេឡង់ លើកទី ១៤ នៅថ្ងៃទី ២០ ដល់ ២៤ ខែ មេសា ឆ្នាំ២០០៨។

- នាយកដ្ឋាន សំរបសំរួលទស្សនៈកិច្ចរបស់លោក Olivier Pêtre និង លោក Daniel Keller ដើម្បីសំរួលដំណើរទស្សនៈកិច្ច វាយតម្លៃចុងក្រោយនៃកម្មវិធី ECAP II ក្នុងជំហានឈានទៅការបង្កើតនូវកម្មវិធី ECAP III ។

- រៀបចំតារាងព័តិមានលំអិតស្តីពី ឈ្មោះ តួនាទី សញ្ញាប័ត្រ និង បុគ្គលិកដែលគ្រោងនឹងជ្រើសតាំងថ្មីរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីផ្ញើជូន លោក Stephane Passeri អ្នកគ្រប់គ្រងកម្មវិធីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា អាស៊ាន - អឺរ៉ុប សំរាប់ជ្រើសរើសចូលរួមវគ្គសិក្សានាពេលខាងមុខ។

- ណាយកដ្ឋាន សហការជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដើម្បីស្នើសុំរៀបចំហ្វឹកហ្វឺនដល់ មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ស្តីពី Vienna Classification ចាប់ពីថ្ងៃទី ២៥ ដល់ ២៧ ខែសីហា ឆ្នាំ ២០០៨ និងដែលមានការផ្តល់ឯកសារ និងវាលគ្និនពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក គឺអ្នកស្រី Noell Moutout (Legal Assistant of Law and International Classifications Division, Sector of Trademarks, Industrial Designs and Geographical Indications, World Intellectual Property Organization)ដែលធ្វើការហ្វឹកហ្វឺន ដល់មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម។

-បានរៀបចំផ្ញើ (Questionnaires) វាយតម្លៃ ការហ្វឹកហ្វឺនដល់មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ស្តីពី Vienna Classification, Nice Classification ដោយអ្នកស្រី Noell Moutout (Legal Assistant of Law and International Classifications Division, Sector of Trademarks, Industrial Designs and Geographical Indications, World Intellectual Property Organization) ដែលបានរៀបចំឡើងពីថ្ងៃទី ២៥ ដល់ ២៧ ខែសីហា ឆ្នាំ ២០០៨ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម ជូនអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

-រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពី សក្តានុពល និង ភាពប៉ះពាល់រវាងច្បាប់ត្រួតពិនិត្យថ្នាំជក់ សារាចរ និងការណែនាំផ្សេងៗ ច្បាប់ស្តីពី ពាណិជ្ជកម្ម ក្នុងការប្រកួតប្រជែងមិនស្មោះត្រង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុនសំរាប់ការធ្វើអោយសេរី ជំរុញ និង ការពារវិស័យវិនិយោគ និងការអនុវត្តន៍អោយមានប្រសិទ្ធិភាពនូវមាត្រា ១១ នៃគម្រោងផែនការអនុសញ្ញាស្តីពី ការត្រួតពិនិត្យលើថ្នាំជក់ (Framework Convention on Tobacco Control) ដែលមានការចូលរួម ពីអនុប្រធានកិច្ចការរួបរួម នាយកកិច្ចការរួបរួម នៃ JTI ប្រចាំតំបន់ អាស៊ីប៉ាស៊ីហ្វិច និង អ្នកគ្រប់គ្រងទូទៅ របស់ JTI ប្រចាំព្រះរាជាណាចក្រកម្ពុជា ជាមួយប្រធានអ្នកតំណាងចំនួន ០៣ រូប ពីក្រុមហ៊ុន BNG, Advocates and Solicitors ជាមួយប្រធាន និងអនុប្រធាននាយកដ្ឋាន កម្មសិទ្ធិបញ្ញា នៅក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ ។

-រៀបចំកិច្ចប្រជុំពិភាក្សាស្តីពី ការអនុវត្តកម្មសិទ្ធិបញ្ញាតាមច្រកព្រំដែន ជាមួយអ្នកស្រី Rachel Bac មកពីការិយាល័យ ទំនាក់ទំនងពាណិជ្ជកម្មអាមេរិក (U.S.T.R) ដែលមានការចូលរួមពីមន្ត្រីជំនាញ ០១ រូប ពីក្រសួងវប្បធម៌

និងវិចិត្រសិល្បៈ ០១ រូប មកពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល. ០១ រូប មកពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករ និង ០១ រូប ទៀតមកពីអគ្គនាយកដ្ឋាន កាំកុងត្រូល ។ គោលបំណងនៃកិច្ចប្រជុំពិភាក្សានេះ គឺផ្តោតសំខាន់ពីស្ថានភាពទូទៅ និង ការអនុវត្តន៏ច្បាប់កម្មសិទ្ធិបញ្ញា តាមព្រំដែនរបស់មន្ត្រីអនុវត្តន៏ច្បាប់កម្មសិទ្ធិបញ្ញា នៃព្រះរាជាណាចក្រកម្ពុជា ។

### ៤. ផ្នែកសមាជិកគណៈកម្មការកម្មសិទ្ធិបញ្ញា

-បានរៀបចំពង្រាងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ដែលមានសមាជិក អន្តរក្រសួងចំនួន ១៤ ចូលរួម។ អនុក្រឹត្យនេះត្រូវបានប្រកាសអោយប្រើ កាលពីថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៨។ មានគោលបំណង នៃអនុក្រឹត្យនេះ ជំរុញ ធានានូវគោលនយោបាយកម្មសិទ្ធិបញ្ញារបស់ជាតិតែមួយ និងពង្រឹងកិច្ចសហការ រវាងក្រសួង ស្ថាប័ន ពាក់ព័ន្ធ ក្នុងការរៀបចំ ផ្សព្វផ្សាយ និង អនុវត្តច្បាប់ និង បទប្បញ្ញត្តិកម្មសិទ្ធិបញ្ញានានា អោយមាន ភាពរលូន និង សមស្របតាម ការសន្យារបស់កម្ពុជា នៅពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំង សហការទទួល និង ប្រើប្រាស់ជំនួយ បច្ចេកទេស ពាក់ព័ន្ធនឹងវិស័យកម្មសិទ្ធិបញ្ញា ពីអង្គការអន្តរជាតិ និង ប្រទេសនានា អោយមានប្រសិទ្ធភាពខ្ពស់។

- បានដំណើរការផ្សព្វផ្សាយអនុក្រឹត្យគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធបញ្ញា ទៅអង្គការអន្តរជាតិ និង ស្ថាប័នរដ្ឋក្នុងស្រុក។

-បានរៀបចំប្រជុំគណៈកម្មការគ្រប់គ្រងផ្នែកកម្មសិទ្ធិបញ្ញា ដើម្បីលើកគំរោងស្នើសុំជំនួយពីសហគមន៍អឺរ៉ុប ក្រោមគំរោងជំនួយរបស់ ECAP III ស្របតាមស្ថានភាព និងតំរូវការជាក់ស្តែង ។

-ធ្វើការផ្សព្វផ្សាយ អនុក្រឹត្យ ស្តីពី ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ជូនដល់មន្ត្រី នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម។

## B-2. ការសំគាល់ភូមិសាស្ត្រទំនិញ

### ក.សេចក្តីព្រាងច្បាប់ស្តីពី ការសំគាល់ភូមិសាស្ត្រទំនិញ

នៅក្នុងឆ្នាំ ២០០៨ នាយកដ្ឋាន ប្រជុំពិនិត្យ ពិភាក្សា និង កែតំរូវច្បាប់ស្តីពី ការសំគាល់ ភូមិសាស្ត្រទំនិញឡើងវិញ ក្រោយពីទទួលបានអនុសាសន៍ ពីសហគមអ៊ឺរ៉ុប អូស្ត្រាលី និង សហរដ្ឋអាមេរិកមានចំនួន ១០លើក។ រីឯនៅថ្ងៃទី ១៤ និងថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០០៨ ក្រុមការងារតាក់តែងច្បាប់បានប្រជុំពិភាក្សា ជាមួយលោកស្រី Veronique FOUKS ជំនាញការបារាំងមកពី INAO អំពីសេចក្តីព្រាងច្បាប់ស្តីពី ការសំគាល់ភូមិសាស្ត្រទំនិញ នៅនាយកដ្ឋាន ក្រោមអធិបតីភាព របស់ លោក វ៉ា រុតសាន ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា។ កិច្ចពិភាក្សានេះផ្តោតលើ ការប្រៀបធៀប រវាងសេចក្តីព្រាង ច្បាប់ស្តីពី ការសំគាល់ភូមិសាស្ត្រទំនិញរបស់កម្ពុជា ជាមួយនឹងអនុស្សាសន៏ ណែនាំរបស់ សហរដ្ឋអាមេរិក អូស្ត្រាលី និង ពិភាក្សាឱ្យកាន់តែស៊ីជម្រៅលើមាត្រាមួយចំនួនរបស់កិច្ចប្រមព្រៀង វិសាលភាពពាណិជ្ជកម្ម ដែលទាក់ទងនឹង កម្មសិទ្ធិបញ្ញា

ដើម្បីឱ្យសេចក្តីព្រាងច្បាប់របស់យើងកាន់តែមានមានសុក្រិតភាព មានភាពបត់បែន និង ងាយស្រួលក្នុងការ អនុវត្តប្រកប ដោយជោគជ័យ ។

### ខ.ការងាររបស់ការិយាល័យសម្គាល់ភូមិសាស្ត្រទំនិញ និងពាណិជ្ជកម្ម

នាយកដ្ឋាន បានរៀបចំលិខិតទូរទាត់ចំណាយរបស់អង្គការ GRET ជារៀងរាល់ខែចាប់ពី ខែមករា ដល់ ខែ ធ្នូ ឆ្នាំ ២០០៨ ផ្ញើទៅ AFD ។ ក្រុមការងាររបស់ការិយាល័យ GIs បានរៀបចំ ផងដែរនូវរបាយការណ៍ប្រចាំខែ ចាប់ពីខែមករា ដល់ខែធ្នូ ឆ្នាំ ២០០៨ ដើម្បីដាក់ជូននាយកដ្ឋានកម្មសិទ្ធិបញ្ញា។ ដោយមានការសហការគ្នាជាមួយមន្ត្រីជំនាញរបស់ក្រុមគាំទ្រគំរោង របស់អង្គការ GRET និងអង្គការ CEDAC មន្ត្រីការិយាល័យ GI ជាមួយក្រុមលេខាធិការដ្ឋាន បានរៀបចំចងក្រង និង ពិនិត្យមើលឡើងវិញជាច្រើនលើកច្រើនសារ លើសៀវភៅបន្ទុក សមាគម លើកកំពស់ម្រេចកំពត និង សៀវភៅបន្ទុកសមាគម លើកកំពស់ស្ករត្នោតកំពង់ស្ពឺ ។

នាយកដ្ឋានក៏បានរៀបចំផងដែរនូវលិខិតអញ្ជើញក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមមហាសន្និបាតបង្កើត សមាគមលើកកំពស់ម្រេចកំពត ដែលបានប្រព្រឹត្តទៅ នៅថ្ងៃទី ០៣ ខែ តុលា នៅភូមិចំការបី សង្កាត់ពងទឹក ខ័ណ្ឌដំណាក់ចង្អើ ក្រុងកែប និង មហាសន្និបាតបង្កើតសមាគមលើកកំពស់ស្ករត្នោត កំពង់ស្ពឺ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨ នៅភូមិត្រពាំងអង្គង់ ឃុំចាន់សែន ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។ នាយកដ្ឋានរៀបចំលិខិតអញ្ជើញក្រុមហ៊ុន និង ស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមសិក្ខា សាលាថ្នាក់តំបន់ ស្តីអំពីការសំគាល់ភូមិសាស្ត្រទំនិញ ដែលបានប្រព្រឹត្តទៅ នៅថ្ងៃទី ១៦-១៧ ខែ តុលា ឆ្នាំ ២០០៨ នៅ សណ្ឋាគារ Cambodiana ក្រុងភ្នំពេញ។

### គ.សកម្មភាពកិច្ចប្រជុំ និង សិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ

នាយកដ្ឋាន បានប្រជុំរៀបចំផែនការជាមុន ដើម្បីចុះអនុវត្តន៏ការតាមមូលដ្ឋាននៅតាមបណ្តា ខេត្តនានា ដូចជា ខេត្តកំពង់ស្ពឺ ខេត្តកំពត និង ក្រុងកែប ធ្វើយ៉ាងណាធានាឱ្យបានការអនុវត្តគំរោងសាកល្បងលើផលិតផល ម្រេចកំពត និងស្ករត្នោតកំពង់ស្ពឺ ទទួលបានជោគជ័យ ។

ក្នុងឆ្នាំ ២០០៨ ការសំគាល់ភូមិសាស្ត្រទំនិញ និងក្រុមគំរោង GI បានចុះរៀបចំកិច្ចប្រជុំពិភាក្សាចំនួន ៩លើក ស្តីអំពី នីតិវិធីចងក្រងសៀវភៅបន្ទុក លក្ខន្តិកៈ និង ផែនការត្រួតពិនិត្យរបស់ សមាគមលើកកំពស់ម្រេចកំពត ដែលបានប្រព្រឹត្តទៅនៅ ខេត្តកំពត និង បាន ជួយរៀបចំបង្កើតសមាគមលើកកំពស់ម្រេចកំពតអោយចេញជារូបរាងឡើង នៅថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០៨។ ស្របពេលជាមួយគ្នានេះដែរ ការសំគាល់ភូមិសាស្ត្រទំនិញ និង ក្រុមគំរោង GI ក៏បានជួយ សំរបសំរួលរៀបចំចងក្រង សៀវភៅបន្ទុក លក្ខន្តិកៈ និង ផែនការត្រួតពិនិត្យរបស់ សមាគមលើកកំពស់ស្ករត្នោត កំពង់ស្ពឺ

ជាមួយក្រុមហ៊ុន (Confirel) និង (DATe) នៅខេត្តកំពង់ស្ពឺ និង បានជួយរៀបចំបង្កើតជាសមគមលើកកំពស់ស្ករត្នោតកំពង់ស្ពឺចេញជារូបរាង នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០៨។

ការសំគាល់ភូមិសាស្ត្រទំនិញ និងក្រុមគំរោង GI រួមសហការជាមួយ ក្រុមការងាររបស់គំរោង TRADE បានចុះស្រាវជ្រាវផលិតផល ដែលមានសក្តានុពល ហើយអាចការពារក្រោម ច្បាប់ស្តីពី ការសំគាល់ភូមិសាស្ត្រទំនិញបានលើខេត្តចំនួន ៤ រួមមាន ខេត្តពោធិសាត់មានៈ ក្រវាំញពោធិសាត់-ថ្មកែវពោធិសាត់ និង ក្រូចពោធិសាត់ "ខេត្តពោធិសាត់" ខេត្តបាត់ដំបង : អង្ករថ្មគោល និង ក្រូចពោធិសាត់ "ខេត្តបាត់ដំបង" ខេត្តបន្ទាយមានជ័យៈ សូត្រភ្នំស្រុក និង ខេត្តសៀមរាបៈ ប្រហុកសៀមរាប នៅថ្ងៃទី ១៦ ដល់២២ ខែមីនា ឆ្នាំ ២០០៨ ។

នាយកដ្ឋានបានចូលរួមប្រជុំជាមួយ ជំនាញការខាងកសិកម្ម របស់អង្គការ JICA ស្តីពីការ រៀបចំដំណើរការសិក្សាពីលទ្ធភាពដាក់អង្ករបាត់ដំបង ជាផលិតផលសំគាល់ភូមិសាស្ត្រទំនិញ នាថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ នៅទីស្នាក់ការអង្គការ JICA ទីក្រុងភ្នំពេញ។

មានការប្រជុំពិភាក្សារវាងក្រុមការងារ GI ជាមួយអ្នកជំនាញខាងកំនត់តំបន់ ភូមិសាស្ត្រដីដើម្បីបង្ហាញតំបន់ដែលអំណោយផលដល់ការផលិតស្ករត្នោតកំពង់ស្ពឺឱ្យមានគុណភាពល្អ និង លទ្ធផលការងារ នៅអង្គការ ខែ វិច្ឆិកា ឆ្នាំ ២០០៨។

### ឃ. ការពង្រឹងសមត្ថភាពមន្ត្រីជំនាញខាងរដ្ឋាភិបាល

មានការវគ្គបណ្តុះបណ្តាលដោយមាន លោក Charles Perraud ជំនាញការមកពី វិទ្យាស្ថានជាតិនៃការហៅតាមប្រភពនៃប្រទេសបារាំង (INAO)ស្តីអំពី ទស្សនៈទាន GI នីតិវិធីកត់ត្រានូវរាល់លក្ខណៈ ពិសេសរបស់ផលិតផល GI សំរាប់ដាក់ចូលទៅក្នុងសៀវភៅបន្ទុក និងនីតិវិធីធ្វើលក្ខន្តិកៈរបស់សមាគម GI ដែលបានប្រព្រឹត្ត ទៅនាថ្ងៃទី ២៦-២៧ ខែ មីនា ឆ្នាំ២០០៨ ដោយមានការចូលរួមពីមន្ត្រីនៃក្រុមគំរោង GI និង ស្ថាប័នពាក់ព័ន្ធ។ មួយវិញទៀត នៅខែ កញ្ញា ឆ្នាំ ២០០៨ ក្រុមការងារ GI បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាល ស្តីពី "ការសំងាត់ពាណិជកម្ម ពតិមានសំងាត់ និង អាជ្ញាប័ណ្ណបញ្ជូសំរាប់សុខភាពសារធារណៈ" នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច។

### ង.សកម្មភាពការងារនៅក្រៅប្រទេស

ទស្សនៈកិច្ចសិក្សាស្តីពី ផលិតផល សំគាល់ភូមិសាស្ត្រនៅប្រទេសបារាំង : ជាលទ្ធផលយើងទាំងអស់គ្នាបានយល់ច្បាស់អំពី ទស្សនាទានផលិតផល GI ការគ្រប់គ្រងសហជីព ផលិតផល GI តួនាទីរបស់ INAO ថ្នាក់ជាតិ និង ថ្នាក់តំបន់ក្នុងការគ្រប់គ្រងផលិតផល GI នីតិវិធីចងក្រងសៀវភៅបន្ទុកនៃផលិតផល GI និង ការរៀបចំប្រព័ន្ធ ត្រួតពិនិត្យផលិតផល GI (ស្វ័យត្រួត ពិនិត្យ ត្រួតពិនិត្យខាងក្នុងនិង ត្រួតពិនិតិងត្រួតពិនិត្យខាងក្រៅ)។ ក្រៅពីនេះ មានការធ្វើទស្សនកិច្ចនៅកន្លែងតាំងពិពណ៌ផលិតផល GI នៅសាលាឃុំ Espelette នៅ Paris Bayonne ចំការម្ទេស Espelette និង ជួបជាមួយផលិតករនៅ Cambo les Bains ដើម្បីស្វែងយល់អំពីបច្ចេកទេសដាំដុះ និង សកម្មភាពផលិតកម្ម នៅមុនពេលចូលជា

សមាជិកសហជីព AOC និង មានទស្សនកិច្ច La maison du jambon de Bayonne ស្ថិតនៅក្នុងតំបន់ Arzacq ដើម្បីស្វែងយល់អំពីរបៀបធ្វើ jambon និង នីតិវិធីចូល ជាសមាជិកសហជីព AOC ។ល។

ទស្សនៈកិច្ចសិក្សានេះបានប្រព្រឹត្តទៅ នាថ្ងៃទី ០១-០៨ ខែឧសភា ឆ្នាំ ២០០៨ នៅប្រទេសបារាំង ដោយមានអ្នកទៅចូលរួម ចំនួន ១៣ រូប (សមាជិកលេខាធិការដ្ឋាន GI : ០៥ រូប តំណាងមន្ទីរកសិកម្មខេត្តកំពត និង ខេត្ត កំពង់ស្ពឺ : ០២ រូប តំណាងអង្គការ CEDAC : ០២ រូប តំណាងអង្គការ GRET : ០១ រូប តំណាង ក្រុមហ៊ុន Confirel ០១ រូប តំណាងក្រុមហ៊ុន FarmLINK : ០១ រូប និង តំណាងផលិតករដាំម្រេច : ០១ រូប) ដឹកនាំដោយ លោក ឡោ រស្មី អគ្គនាយករងបច្ចេកទេស ក្រសួងកសិកម្ម ។

**ច.ការលើកកំពស់ទស្សនៈការសំគាល់ភូមិសាស្ត្រទំនិញ និង ការផ្សព្វផ្សាយ បទពិសោធន៍**

នាថ្ងៃទី ១៩-២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ មានការតាំងពិពរណ៍ផលិតផលម្រេចកំពត និង ស្ករត្នោតកំពង់ស្ពឺ ដើម្បីបង្ហាញដល់បណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ក្នុងសន្និសិទថ្នាក់រដ្ឋមន្ត្រី នៃប្រទេសអភិវឌ្ឍន៍តិចតួច ស្តីពី ជំនួយសំរាប់ពាណិជ្ជកម្ម របៀបវារៈឧស្សាហកម្មសំរាប់ប្រទេសអភិវឌ្ឍន៍តិចតួច នៅសណ្ឋាគារសុខា នៅខេត្តសៀមរាម ។

**ឆ. ការលំបាកផ្សេងៗនៅក្នុងប្រតិបត្តការរបស់ការិយាល័យសំគាល់ភូមិសាស្ត្រទំនិញ និង ការសំងាត់ពាណិជ្ជកម្ម**

សេចក្តីព្រាងច្បាប់ស្តីពី ការសំគាល់ភូមិសាស្ត្រទំនិញ ត្រូវបានជួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស ពីរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង តាមរយៈទីភ្នាក់ងារបារាំងដើម្បីការអភិវឌ្ឍន៍ តាំងពីចុងឆ្នាំ ២០០៤ មកម្លេះ ហើយត្រៀម នឹងដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីនៅចុងឆ្នាំ ២០០៧ ប៉ុន្តែការសំរេចចិត្តនេះ ត្រូវបានពន្យារពេលទៅចុងឆ្នាំ ២០០៨ ខាងមុខនេះវិញ។

ដោយសារច្បាប់នេះជាច្បាប់មួយ ការពារការធ្វើពាណិជ្ជកម្មដោយស្របច្បាប់លើទំនិញកសិ-ចំណីអាហារ ទំនិញសិប្បកម្ម និង ទំនិញផ្សេងៗទៀត ដែលទាក់ទងដល់ប្រវត្តិសាស្ត្រ វប្បធម៌ និងប្រពៃណី របស់ក្រុមផលិតករ អាជីវករនៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់មួយនៅក្នុងប្រទេសកម្ពុជា និង អន្តរជាតិ ទើបការពិភាក្សាគ្នារវាង ក្រុមការងារកសាងច្បាប់ និងបណ្តាជំនាញការរបស់ INAO ដែលជាការិយាល័យមួយរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ទទួលខុសត្រូវក្នុងការតាក់តែងសេចក្តីព្រាងច្បាប់ លើកទី ១ និង បណ្តាជំនាញការរបស់កម្មវិធីសហប្រតិបត្តការលើវិស័យកម្មសិទ្ធិបញ្ញា របស់អាស៊ាន និងសហគមន៍អឺរុប ECAP នៅមានបញ្ហាប្រទាំងប្រទើសគ្នា មួយចំនួន ដែលត្រូវដោះស្រាយ ។

យោងតាមការពិភាក្សាគ្នា ជាច្រើនលើកច្រើនសារលើសេចក្តីព្រាងច្បាប់នេះ និង ដោយធ្វើការប្រៀបធៀបគ្នាជាមួយច្បាប់ស្តីពី ការសំគាល់ភូមិសាស្ត្រទំនិញរបស់ប្រទេសជិតខាងនៅក្នុងតំបន់ ដូចជារាជាណាចក្រថៃឡង់ដ៏ សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងធ្វើការផ្ទៀងផ្ទាត់ជាមួយអនុស្សាសន៍ និងសេចក្តីណែនាំ របស់ជំនាញការច្បាប់របស់សហរដ្ឋអាមេរិក និងអូស្ត្រាលី និងសិក្សាស្រាវជ្រាវលើមាត្រាច្បាប់ របស់វិសាលភាពពាណិជ្ជកម្ម ដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម TRIPS ដើម្បីរាវរកចំនុចខ្លាំង ចំនុចខ្សោយ ដើម្បីកែលំអ និង បំពេញបន្ថែម

លើរាល់ចំនុចខ្វះខាតនៅក្នុងជំពូក និង មាត្រាមួយចំនួននៅក្នុងសេចក្តីព្រាងច្បាប់នេះ ឱ្យកាន់តែកាន់តែគ្រប់ជ្រុងជ្រោយមានភាពរលូន បត់បែនតាមសភាពការណ៍វិវឌ្ឍន៍ និង ងាយស្រួលក្នុង ការអនុវត្តន៍នាពេលអនាគតប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ឋ. ទិសដៅការងាររបស់ការិយាល័យសំគាល់ភូមិសាស្រ្តទំនិញ និង ការសំងាត់ពាណិជ្ជកម្ម សម្រាប់អនុវត្តនៅក្នុងឆ្នាំ ២០០៩**

ក្នុងឆ្នាំ ២០០៩ នេះ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នឹងបញ្ជូន សេចក្តីព្រាងច្បាប់ស្តីពី ការសំគាល់ភូមិសាស្រ្តទំនិញ និងនៅត្រីមាសទី២ រឺ ទី៣ នាយកដ្ឋានកម្មសិទ្ធិបញ្ញា នឹងបញ្ជូនសេចក្តី ព្រាងអនុក្រឹត្យស្តីពី ការសំគាល់ភូមិសាស្រ្តទំនិញ ទៅក្នុងរបៀបវារៈកិច្ចប្រជុំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ការិយាល័យសំគាល់ ភូមិសាស្រ្តទំនិញ មានផែនការ ជួយសមាគមលើកកំពស់ម្រេចកំពត និងសមាគមលើកកំពស់ស្ករត្នោត កំពង់ស្ពឺ ក្នុងការពង្រឹង សមត្ថភាពបណ្តុះសមាជិករបស់សមាគមទាំងផ្នែកគ្រប់គ្រងដំណើរការផលិតឱ្យមានគុណភាពស្រប តាមសៀវភៅបន្ទុកជួយ សមាជិក សមាគមរៀបចំយុទ្ធសាស្រ្តទីផ្សារ និងផ្សព្វផ្សាយបន្តនូវទស្សនាទានស្តីពី ការសំគាល់ភូមិ សាស្រ្តទំនិញជូនចំពោះ សមាជិកថ្មីរបស់សមាគម។

ការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីអនុវត្តន៍មុខទំនិញមួយចំនួនដូចជាៈ ធូរេន កំពត អង្ករផ្ការម្ដួលខេត្តបាត់ដំបង ប្រហុកអប់ខេត្តសៀមរាប សូត្រភ្នំស្រុក និង ប៉ូលខេត្តតាកែវ ដែលមានសក្តានុពល ដ៏សំបើម សម្រាប់ចុះជាទំនិញសំគាល់ភូមិសាស្រ្តក្រោមការការពារដោយច្បាប់ស្តីពី ការសំគាល់ភូមិសាស្រ្តទំនិញ។

**C-៣. កិច្ចការរដ្ឋបាល -ហិរញ្ញវត្ថុ :**

**១-ធនធានមនុស្ស :**

ចំនួនមន្ត្រីរាជការ:

- ក្នុងឆ្នាំ ២០០៨ ចំនួនមន្ត្រីរាជការសរុប ៦៥ រូប ក្នុងនោះ មន្ត្រីថ្នាក់នាយកដ្ឋាន ចំនួន ០៥ រូប និង ថ្នាក់ការិយាល័យ ចំនួន ២៣ រូប និង មន្ត្រីផ្ទេរមកពីនាយកដ្ឋានផ្សេងចំនួន ០១ រូប។

អង្គការ WIPO បានបញ្ជូនជំនាញការមកតបណ្តាញ Network និង បញ្ចូលកម្មវិធី Industrial Property Administration System (IPAS) ដើម្បីសំរួលក្នុងការត្រួតពិនិត្យម៉ាកបានរួចរាល់ហើយ។

**២-ការងារថវិកា :**

ដោយគិតចាប់ពីថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ រហូតដល់ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៨ នាយកដ្ឋានបានបង់ប្រាក់ជូននាយកដ្ឋានរដ្ឋបាល ចំនួន **728,920,000.00៛** ( ប្រាំពីររយម្ភៃប្រាំបីលានប្រាំបួនរយម្ភៃពាន់រៀល ) ដែលក្នុងនោះមាន :

- កំរៃនៃការដាក់ពាក្យសុំចុះបញ្ជីម៉ាក : 61,980,000.00៛
- កំរៃនៃការចុះបញ្ជីម៉ាក : 415,980,000.00៛
- កំរៃនៃការបញ្ជាក់ ការប្រើប្រាស់ម៉ាក : 65,120,000.00៛

- កំរៃនៃការផ្ទេរកម្មសិទ្ធិម៉ាក : 9,960,000.00៛
- កំរៃនៃការប្តូរឈ្មោះម្ចាស់ម៉ាក : 17,320,000.00៛
- កំរៃនៃការកែតំរូវនានា : 1,400,000.00៛
- កំរៃនៃការក្នុងការប្តូរអស័យដ្ឋាន : 13,960,000.00៛
- កំរៃក្នុងការលុបម៉ាកចេញពីបញ្ជី : 3,800,000.00៛
- កំរៃក្នុងការចុះបញ្ជីសាឡើងវិញ : 139,400,000.00៛

**សរុបៈ 728,920,000.00៛**

**សន្និដ្ឋាន :**

ប្រៀបធៀបនឹងការកំណត់បង់ចំណូលជូនរដ្ឋសំរាប់ ឆ្នាំ ២០០៧ ដែលមានចំនួន **573,160,000.00រៀល** ឃើញថា យើងអនុវត្តបានលើស **155,760,000.00៛** ស្មើនឹង ២៧,១ ភាគរយ។ អាស្រ័យ ដោយក្នុងឆ្នាំ ២០០៨ យើងបានទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកមានការកើនឡើង និង ដោយការអនុវត្តន៏តាមប្រកាសរួមក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីកំរៃរដ្ឋបាលក្នុងការចុះបញ្ជីម៉ាក និង កំរៃរដ្ឋបាល ពាក់ព័ន្ធ។

**៣-ការងារបោះពុម្ពផ្សាយព្រឹត្តិប័ត្រផ្លូវការ**

ជាផ្នែកមួយតម្រូវដោយច្បាប់ ដើម្បីអោយការចុះបញ្ជីម៉ាក មានតម្លាភាព ទុកលទ្ធភាពអោយភាគីទី៣ មានសិទ្ធិប្តឹងជំទាស់ទៅនឹងការចុះបញ្ជីម៉ាក នាយកដ្ឋានបាន បោះពុម្ពព្រឹត្តិប័ត្រផ្លូវការ (Official Gazette) បានសរុប ចំនួន ១១ លេខ គឺ ពីលេខ **៩៧** ដល់ **១០៧** ដើម្បីផ្សព្វផ្សាយជាសាធារណៈ។ លើសពីនេះទៅទៀត នាយកដ្ឋានបានបញ្ចូលទិន្នន័យ នៃការផ្សព្វផ្សាយទាំងនេះ ចូលទៅជា CD សំរាប់ជូនអតិថិជនផងដែល។

**D-៤. កិច្ចការជំនាញពាណិជ្ជសញ្ញា :**

**១-ការចុះបញ្ជីពាណិជ្ជសញ្ញា**

ក្នុងឆ្នាំ ២០០៨ នាយកដ្ឋានបាន :

**ក-ទទួលពាក្យស្នើសុំថ្មី :** ៣០៩៩ ម៉ាក

-ក្នុងស្រុកៈ ៥៧៨ ម៉ាក ក្រៅស្រុកៈ ២៥២១ ម៉ាក

-ម៉ាកដែលមិនទាន់បានចុះបញ្ជី : ម៉ាក

**ខ- ឯកភាពចុះបញ្ជីម៉ាកស្នើសុំថ្មី :** ២៣១១ ម៉ាក

ក្នុងស្រុក ៤៣៧ ម៉ាក ក្រៅស្រុក ១៨៧៤ ម៉ាក

**គ- កិច្ចការក្រោយចុះបញ្ជី**

- ការប្តូរឈ្មោះអាស័យដ្ឋាន : ៣៤៩ ម៉ាក
- ការបញ្ជាក់លើការប្រើប្រាស់ រឺមិនបានប្រើប្រាស់ម៉ាក : ១៦២៨ ម៉ាក
- ការកែតំរូវ : ៣៥ ម៉ាក
- ការផ្ទេរសិទ្ធិ ម្ចាស់ម៉ាក : ២៤៩ ម៉ាក
- ការប្តូរឈ្មោះ រឺបញ្ចូលគ្នានៃម្ចាស់ម៉ាក : ៤៣៣ ម៉ាក
- ការចុះបញ្ជីម៉ាកសាឡើងវិញ : ៦៩៧ម៉ាក
- ការលុបម៉ាក : ១៩ ម៉ាក

**សន្និដ្ឋាន :**

ប្រៀបធៀបទៅនឹង ឆ្នាំ ២០០៧ ដែលទទួលពាក្យបានតែ ២៧៥៨ ម៉ាក ឃើញថា កើនឡើង ចំនួន ៣៤៧ ម៉ាក ស្មើនឹង ១២,៣ ភាគរយ ។ ឯការចុះញ្ជីម៉ាកវិញ ឆ្នាំ ២០០៧ ចុះបញ្ជីបានចំនួន ១៣៧៨ ម៉ាក កើនឡើងចំនួន ៩៣៣ ម៉ាក ស្មើនឹង ៦៧,៧ ភាគរយ ។ ក្នុងឆ្នាំ ២០០៨ កិច្ចការនេះ អនុវត្តបានល្អប្រសើរឡើងវិញ ដោយមន្ត្រីនាយកដ្ឋានស្គាល់ប្រព័ន្ធថ្មីនេះ ចេះប្រើប្រាស់កាន់តែយល់ច្បាស់ ។

ចំណែកឯម៉ាកក្នុងស្រុក ដែលបានទទួលក្នុងឆ្នាំ ២០០៨ មានចំនួន ៥៧៨ ម៉ាក ។ រីឯការទទួលពាក្យម៉ាកស្រុកក្នុងស្រុក ឆ្នាំ ២០០៧ បានចំនួនតែ ៥៥២ ម៉ាក ឃើញថា មានការកើនឡើងចំនួន ២៦ ម៉ាក ដែលអាចឆ្លុះបញ្ចាំងឃើញថា សេដ្ឋកិច្ចកម្ពុជា មានភាពរីកចំរើនពិសេសក្នុងវិស័យផលិតកម្ម និង សេវាកម្ម ព្រមទាំងការយល់ដឹងពីអត្ថប្រយោជន៍ក្នុងការចុះបញ្ជីម៉ាក របស់អាជីវករ ផលិតករ តាមរយៈការផ្សព្វផ្សាយច្បាប់កម្មសិទ្ធិបញ្ញា ជាច្រើនឆ្នាំកន្លងមក ។

## E- ៥. ការដោះស្រាយវិវាទរំលោភបំពានកម្មសិទ្ធិបញ្ញា និង ការលុបម៉ាកចេញពីបញ្ជី

ក្រោមវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលប្រទេសកម្ពុជាសមាជិកនោះ រាល់របាំងពាណិជ្ជកម្ម ត្រូវបានដកចេញ នាំអោយលំហូរពាណិជ្ជកម្មអន្តរជាតិមានលក្ខណៈសេរី ដែលប្រការនេះ បានជះឥទ្ធិយ៉ាងធ្ងន់ធ្ងរដល់ផលិតករ និង អាជីវករក្នុងស្រុក តើរដ្ឋាភិបាលត្រូវធ្វើយ៉ាងណា? ដើម្បីការពារ និងលើកទឹកចិត្តដល់ផលិតករ និងអាជីវករក្នុងស្រុកបាន ។

កម្មសិទ្ធិបញ្ញា ជាកម្មសិទ្ធិ ( ទ្រព្យសម្បត្តិ ) ឯកជន ដែលប្រព័ន្ធច្បាប់កម្មសិទ្ធិបញ្ញា ការពារលើកទឹកចិត្ត និងអនុញ្ញាត អោយម្ចាស់កម្មសិទ្ធិបញ្ញាទាំងនោះ យកទៅប្រកបអាជីវកម្មក្នុងដែនសិទ្ធិដែលខ្លួនមាន ហើយអ្នកដទៃមិនអាចរំលោភបំពានបានឡើយ ។ ដូច្នេះ ច្បាប់កម្មសិទ្ធិបញ្ញា ធានាការពារទាំងផលិតករ និង អាជីវករក្នុងស្រុក ទាំងអ្នកក្រៅស្រុក អោយប្រកបអាជីវកម្មក្រោមកម្មសិទ្ធិបញ្ញារបស់ខ្លួន ប្រសិនបើអ្នកដទៃបំពានកម្មសិទ្ធិរបស់ខ្លួន ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលសិទ្ធិត្រូវជាអ្នកផ្តួចផ្តើមស្វះស្វែងរកចំណាត់ការផ្លូវច្បាប់ ទប់ស្កាត់ការរំលោភសិទ្ធិបញ្ញារបស់ខ្លួនជាបន្ទាន់ ។

ផលិតករ និងអាជីវករមិនត្រឹមតែស្រាវជ្រាវ និងបង្កើតម៉ាក បច្ចេកវិជ្ជា និងស្នាដៃថ្មីៗ យកមក ចុះបញ្ជីការពារ ឬការពារដោយស្វ័យប្រវត្តិ ជាទុនមូលដ្ឋានដ៏សំខាន់ក្នុងការបង្កើត និងអភិវឌ្ឍន៍នូវទំនិញ ឬសេវាប្រកបដោយគុណភាពខ្ពស់ជាប្រចាំ ដើម្បីផ្គត់ផ្គង់ក្នុងទីផ្សារប៉ុណ្ណោះទេ ប៉ុន្តែដើម្បីការពារផលប្រយោជន៍របស់ខ្លួន និង សុវត្ថិភាពអ្នកប្រើប្រាស់ម្ចាស់កម្មសិទ្ធិបញ្ញានីមួយៗ ត្រូវមានតួនាទីរួមចំណែកជា មួយស្ថាប័នអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា ក្នុងការឃ្លាំមើលនូវសកម្មភាពរំលោភបំពានកម្មសិទ្ធិបញ្ញារបស់ខ្លួនជាប្រចាំ ។ ប្រសិនបើបណ្តោយអោយសកម្មភាពរំលោភកម្មសិទ្ធិបញ្ញាទាំងនោះ នៅតែបន្តនោះ តំលៃនៃកម្មសិទ្ធិបញ្ញារបស់ខ្លួន នឹងត្រូវចុះខ្សោយទៅៗ និងឈានដល់ការបាត់បង់តំលៃរបស់វា ហើយកម្មសិទ្ធិបញ្ញាទាំងនោះ នឹងលែងទទួលបាននូវការគាំទ្រពីអ្នកប្រើប្រាស់ ដោយសារតែការក្លែងក្លាយកម្មសិទ្ធិបញ្ញាលើទំនិញ ឬសេវា ដែលគ្មានការធានានូវគុណភាព និងសុវត្ថិភាពដល់អ្នកប្រើប្រាស់ ។

ក្រោមការដឹកនាំរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលការិយាល័យវិវាទជាចំណុះ ទើបតែបានបង្កើតនៅចុងឆ្នាំ ២០០៧ នេះ ក្នុងបំណងដោះស្រាយរាល់វិវាទកម្មសិទ្ធិបញ្ញា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម តាមរយៈការសំរុះសំរួលគ្នាជាមុន មុននឹងឈានដល់ចំណាត់ការតាមប្រព័ន្ធតុលាការ គឺជាមធ្យោបាយដ៏ត្រឹមត្រូវមួយ ដែលបណ្តាប្រទេសនានាកំពុងប្រកាន់យក ។ ទិន្នន័យនៃការដោះស្រាយវិវាទ គឺជាទិន្នន័យមានតួនាទីជាមូលដ្ឋានក្នុងការប្រតិបត្តិការងារ នៃការិយាល័យវិវាទ ក៏ដូចជាការិយាល័យផ្សេងៗទៀត នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញាផងដែរ។

លទ្ធផលជាក់ស្តែង ក្នុងឆ្នាំ ២០០៨ នេះ ការិយាល័យវិវាទបានខិតខំរៀបចំសំណុំរឿងនីមួយៗ សាជាថ្មី ដោយកត់ត្រាលេខលំដាប់ និងចងក្រងទិន្នន័យនៃការដោះស្រាយវិវាទអោយមានលក្ខណៈជាប្រព័ន្ធនៅក្នុងកម្មវិធី Excel បានរួចរាល់ហើយ ដែលការរៀបចំទាំងនេះបង្កលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវរកម៉ាក ដែលបានលុបចេញពីបញ្ជី ម៉ាកដែលបានកែតំរូវ ឬម៉ាកដែលត្រូវរំលោភបំពាន ហើយទិន្នន័យទាំងនេះ ត្រូវបានយកទៅធ្វើជាមូលដ្ឋានផងដែរ ក្នុងការបន្ថែមសកម្មភាព ឬការកំណត់ស្ថានភាពនៃការចុះបញ្ជី ម៉ាកនៅក្នុងប្រព័ន្ធ IPAS ដែលការវិវត្តន៍ទាំងនេះ បានធានាដល់ភាពមានប្រសិទ្ធិភាពក្នុងការងាររបស់ការិយាល័យចំណុះនាយកដ្ឋានទាំងអស់ អោយកាន់តែប្រសើរឡើង ក៏ដូចជាការសិក្សាស្រាវជ្រាវសំរាប់សិស្សកម្មសិក្សា និងសាធារណៈជន។

លើសពីនេះ ការិយាល័យវិវាទ ក៏បានបង្កើនល្បឿនក្នុងការពិនិត្យ ដោះស្រាយពាក្យបណ្តឹងស្នើសុំទប់ស្កាត់ការរំលោភបំពានម៉ាកក៏ដូចជាពាក្យបណ្តឹងលុបម៉ាក អោយបានឆាប់ជៀសវាងការកកស្ទះ និងបានរៀបចំកត់ត្រា និងចាត់ការពាក្យបណ្តឹងអោយមានលំហូរទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ និងមានលក្ខណៈជាប្រព័ន្ធ ។

ការិយាល័យវិវាទ ក៏បានទទួលពាក្យបណ្តឹងស្នើសុំទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញា បានចំនួន **១៤** ករណី ហើយដោះស្រាយការរំលោភបំពានបានចំនួន **១២**ករណី ក្នុងនោះរួមមាន ការបដិសេធន៍ ១ ករណី ព្រោះដើមចោទបានបង្ហាញ

ទីតាំងរបស់ចុងចំលើយមិនត្រូវទាត់ចោល ១ ករណី ដោយសារម្ចាស់ម៉ាក បានបាត់បង់សិទ្ធិ ហើយនៅសល់ ៥ ករណី ទៀត ការិយាល័យកំពុងបន្តពិនិត្យ និងដោះស្រាយ ។

ការិយាល័យវិវាទក៏បានទទួលពាក្យបណ្តឹងលុបម៉ាកបានចំនួន **១៥** ករណី មានចំនួន **២០** ម៉ាក និង ពិនិត្យដោះស្រាយ បានចំនួន ១៦ ករណី ស្មើនឹង ២២ ម៉ាក ក្នុងនោះរួមមាន ការលុបម៉ាកចេញពីបញ្ជីបានចំនួន ១០ ករណី ស្មើនឹង ១៥ ម៉ាក កែតំរូវ ១ ករណី ស្មើ ១ ម៉ាក ការដកពាក្យដោយដើមបណ្តឹងចំនួន ១ ករណី ស្មើនឹង ២ ម៉ាក ការបដិសេធន៍ពាក្យបណ្តឹង ចំនួន ៣ ករណី ស្មើនឹង ៣ ម៉ាក ព្រោះពាក្យបណ្តឹង ទាំងនេះមានឯកសារមិនគ្រប់គ្រាន់ និងទាត់ចោល ១ ករណី ស្មើនឹង ១ ម៉ាក ដោយហេតុថា ពាក្យបណ្តឹង មិនមានមូលដ្ឋានផ្លូវច្បាប់គ្រប់គ្រាន់ដែលអាចប្តឹងលុបម៉ាករបស់ចុងចំលើយបានឡើយ។ នៅសល់ **៩** ករណី ស្មើនឹង ១១ ម៉ាក ទៀត កំពុងបន្តពិនិត្យ និងដោះស្រាយ ។

បើប្រៀបធៀបការទទួលពាក្យបណ្តឹងរំលោភបំពានពាណិជ្ជសញ្ញា ក្នុងឆ្នាំ ២០០៨ នេះ នឹងឆ្នាំ ២០០៧ គឺកើនឡើង ចំនួន ៤ ករណី ហើយការទទួលពាក្យបណ្តឹងលុបម៉ាកចេញពីបញ្ជី គឺកើនឡើងចំនួន ៥ ករណី ។ ចំណែកលទ្ធផលនៃ ការដោះស្រាយការរំលោភបំពានក្នុងឆ្នាំ ២០០៨ មានចំនួន ១០ ករណី គឺកើនឡើងចំនួន ៣ ករណី ប្រៀបធៀបនឹងឆ្នាំ ២០០៧ ឯការលុបម៉ាកចេញពីបញ្ជីមានចំនួន ១០ ករណី ស្មើនឹង ១៥ម៉ាក គឺកើនឡើងចំនួន ២ ម៉ាក នេះជាសូចនាករមួយ បង្ហាញអោយឃើញថា សកម្មភាពពាណិជ្ជកម្មមានភាពរីកលូតលាស់ជាងមុន ទន្ទឹមនឹងនេះ ការរំលោភបំពានកម្មសិទ្ធិបញ្ញាក៏ មានការកើនឡើងផងដែរ ឬថាការយល់ ដឹងផ្នែកកម្មសិទ្ធិបញ្ញាក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមជ្រាបចូលក្នុងស្រទាប់មហាជន ជាសន្សឹមៗ ហើយម្ចាស់កម្មសិទ្ធិបញ្ញាបានចាប់អារម្មណ៍ដល់ការការពារផលប្រយោជន៍របស់ខ្លួន ដោយផ្តួចផ្តើមចាត់វិធានការ ចំពោះការរំលោភបំពានទាំងនោះ ទៅតាមស្ថាប័នអនុវត្តកម្មសិទ្ធិបញ្ញា ដែលមានស្រាប់។

**សន្និដ្ឋាន**

ថ្វីត្បិតតែការិយាល័យវិវាទ នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ខិតខំបំពេញការងាររបស់ខ្លួន បាននាំមកនូវការវិវត្តន៍ដ៏ល្អ ប្រសើរក៏ដោយ ក៏ការិយាល័យនេះ នៅមានការងារជាច្រើនទៀត ត្រូវបំពេញអោយ បានទាន់ការវិវត្តន៍នៃកម្មសិទ្ធិបញ្ញា ជាសកល និងការរីករាលដាលនៃការរំលោភបំពានកម្មសិទ្ធិបញ្ញា ទាមទារអោយមានមន្ត្រីដែលមានសមត្ថភាពមកបំរើការងារ បន្ថែមទៀត។

សកម្មភាពរំលោភបំពានកម្មសិទ្ធិបញ្ញា នៅក្នុងប្រទេសកម្ពុជា នៅតែជាបញ្ហាធ្ងន់ធ្ងរនៅឡើយ ហើយការអនុវត្តន៍ កម្មសិទ្ធិបញ្ញាមិនអាចប្រព្រឹត្តទៅបានដោយរលូនទេ ប្រសិនបើម្ចាស់កម្មសិទ្ធិបញ្ញា នៅតែប្រងើយកន្តើយចំពោះការរំលោភ បំពានទាំងនោះ គួរតែម្ចាស់កម្មសិទ្ធិបញ្ញាសហការជាមួយសមត្ថកិច្ច ដើម្បីទប់ស្កាត់ការរំលោភបំពានអោយកាន់តែមាន ប្រសិទ្ធិភាព ដើម្បីលើកស្ទួយការបង្កើតសម្បត្តិកម្មសិទ្ធិបញ្ញា និង ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

**ទិសដៅការងារសំរាប់ឆ្នាំ ២០០៩**

ដើម្បីធានាដល់ប្រសិទ្ធភាពការងាររបស់ការិយាល័យវិវាទអោយមានភាពរលូន ការិយាល័យនេះ មានទិសដៅ ដូចខាងក្រោម :

- បង្កើនល្បឿនក្នុងការពិនិត្យដោះស្រាយពាក្យបណ្តឹង ស្នើសុំទប់ស្កាត់ការរំលោភបំពានម៉ាក ក៏ដូចជាពាក្យបណ្តឹងលុបម៉ាក អោយបានឆាប់ជៀសវាងការកកស្ទះ ដែលជះឥទ្ធិពលមិនល្អដល់ការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ។

- រក្សានិរន្តរភាពរៀបចំកត់ត្រា គ្រប់គ្រង និងចាត់ការពាក្យបណ្តឹងអោយមានលំហូរទៅតាមនីតិវិធី ដែលកំណត់ដោយច្បាប់ និងមានលក្ខណៈជាប្រព័ន្ធ ។

- បន្តតាមដានដាក់លក្ខខ័ណ្ឌដល់ការចុះបញ្ជីម៉ាក ដែលមានវិវាទ ក្នុងប្រព័ន្ធ IPAS ដើម្បីធានាដល់ប្រសិទ្ធភាពការងាររបស់ការិយាល័យចំណុះនាយកដ្ឋានកម្មសិទ្ធិបញ្ញា ។

- ក្រើនរំលឹកដល់មន្ត្រីអោយកែតំរូវផ្នត់គំនិតអសកម្ម ដោយប្រកាន់យកវប្បធម៌សហការការងារជាសារវ័ន្ត ស្រាវជ្រាវបង្កើនការយល់ដឹងផ្នែកដោះស្រាយវិវាទកម្មសិទ្ធិបញ្ញា ដើម្បីសំដែងការងារអោយកាន់តែមានប្រសិទ្ធភាព ។

- ប្រកាន់ខ្ជាប់វប្បធម៌ណែនាំ បញ្ចុះបញ្ចូលអោយអ្នករំលោភបំពានផ្នែកកម្មសិទ្ធិបញ្ញា ប្រែក្លាយខ្លួនអោយទៅជាម្ចាស់កម្មសិទ្ធិបញ្ញា ដែលជាកញ្ចប់ទុនជាតិមួយ ក្នុងការអភិវឌ្ឍនីសេដ្ឋកិច្ចជាតិ ។

- សហការជាមួយការិល័យដែលពាក់ព័ន្ធ ក្នុងផ្សព្វផ្សាយ និងបណ្តុះបណ្តាលកម្មសិទ្ធិបញ្ញា ដល់សិក្ខាកាម និងសាធារណជន ។

**តារាង ក**

| ស្ថិតិនៃការរំលោភបំពានកម្មសិទ្ធិបញ្ញាក្នុងឆ្នាំ ២០០៨ | | | | |
|---|---|---|---|---|
| ឆ្នាំ | ការទទួលពាក្យបណ្តឹង | ការដោះស្រាយ | | នៅសល់ |
| | | ការបដិសេធន៍ និងដកពាក្យបណ្តឹង | ការសំរបសំរួល | |
| ២០០៧ | ៣ | | | |
| ២០០៨ | ១៤ | ២ | ១០ | |
| **សរុប** | **១៧** | **២** | **១០** | **៥** |

**តារាង ខ**

| ស្ថិតិនៃការលុបម៉ាកក្នុងឆ្នាំ ២០០៨ | | | | |
|---|---|---|---|---|
| | | ការដោះស្រាយ | | |

| ឆ្នាំ | ការទទួលពាក្យបណ្តឹង | | ការបដិសេធន៍ និង ដកពាក្យបណ្តឹង[១] | | លុប | | កែតំរូវ | | នៅសល់ | |
|---|---|---|---|---|---|---|---|---|---|---|
| | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក | ករណី | ម៉ាក |
| **២០០៧** | **១០** | **១៣** | | | | | | | | |
| **២០០៨** | ១៥ | ២០ | ៥ | ៦ | ១០ | **១៥** | **១** | **១** | | |
| **សរុប** | **២៥** | **៣៣** | **៥** | **៦** | **១០** | **១៥** | **១** | **១** | **៩** | **១១** |

*១ : ការបដិសេធន៍ពាក្យបណ្តឹងជាបឋម ការទាត់ចោលពាក្យបណ្តឹងដែលមានមូលដ្ឋានមិនអាចលុបម៉ាកបាន និងការសុំដកពាក្យបណ្តឹង ដោយសាម៉ីខ្លួន ។*

## II. ទិសដៅអនុវត្តការងារសំរាប់ ឆ្នាំ ២០០៨

នាយកដ្ឋានមានទិសដៅអនុវត្តការងារ ដូចខាងក្រោម :

**ក -<u>ការងារកសាងសិក្សាច្បាប់ និង បទបញ្ញត្តិកម្មសិទ្ធិបញ្ញា ផ្សេងៗ</u> :**

**១-ការងារកសាងសិក្សាច្បាប់ និង បទបញ្ញត្តិកម្មសិទ្ធិបញ្ញា ផ្សេងៗ :**

**ក១-** បន្តបញ្ចប់ការរៀបចំច្បាប់ស្តីពី ការសំគាល់ភូមិសាស្ត្រទំនិញ (Law on Geographical Indications) និង ដាក់ជូនសុំការអនុម័តពីគណៈរដ្ឋមន្ត្រី និង សភាជាតិក្នុងដើមឆ្នាំ ២០០៩។

**ក២-**បន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការការពារ ការសម្ងាត់ពាណិជ្ជកម្ម និង ពត៌មានសំងាត់ (Law on the Protection of Trade Secrets and Undisclosed Information) និង ពិនិត្យឡើងវិញទៅលើសេចក្តីព្រាងច្បាប់ជាភាសាខ្មែរអោយបានកាន់តែ ល្អិតល្អន់ និងកាន់តែស៊ីជំរៅ និងរាវរកផលប៉ះពាល់ទាំងឡាយណា ទៅលើច្បាប់ដែលមានស្រាប់របស់អន្តរក្រសួងនីមួយៗ និងឈាន ទៅបញ្ចប់សេចក្តីព្រាងច្បាប់នេះជាស្ថាពរនា ឆ្នាំ២០០៩ នេះ។

**ក៣**-សិក្សាស្រាវជ្រាវក្នុងការរៀបចំអនុក្រឹត្យ ស្តីពី "វិធានការណ៍តាមព្រំដែន" ដែលចែងលំអិតអំពី នីតិវិធីអនុវត្តការទប់ស្កាត់ការរំលោភបំពានកម្មសិទ្ធិបញ្ញាតាមព្រំដែន ដោយអនុញ្ញាតឱ្យម្ចាស់សិទ្ធិលើម៉ាក ប្រកាស នីយប័ត្រតក្កកម្ម និង សិទ្ធិអ្នកនិពន្ធ ដាក់ពាក្យទៅអាជ្ញាធរគយ ឬ កាំកុងត្រូលជាមុន ដើម្បីផ្អាកការនាំចូលទំនិញ ដែលសង្ស័យ ឬ មានការរំលោភបំពានកម្មសិទ្ធិបញ្ញា។

**ក៤**- សិក្សាស្រាវជ្រាវក្នុងការរៀបចំអនុក្រឹត្យ ស្តីពី " ការត្រួតពិនិត្យ ការផលិត ការនាំចូល ថាស (CDs) " ក្នុងគោលបំណងការពារកុំឱ្យកម្ពុជា ក្លាយជាប្រទេសផលិត CDs ក្លែងក្លាយក្នុងបរិមាណច្រើន ហើយនាំចេញទៅ ប្រទេសក្រៅ។

**ក៥**- ជំរុញ និង សហការណ៍ជាមួយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ នាយកដ្ឋានសិទ្ធិអ្នកនិពន្ធ ក្នុងការរៀបចំព្រាងអនុក្រិត្យ ស្តីពី "ការបង្កើតអង្គភាពគ្រប់គ្រងសិទ្ធិរួម" ក្នុងគោលបំណងប្រមូលលាភការ ដល់អ្នកសំដែង និងអ្នកផលិតហ្វូណូក្រាម។

**ក៦**- បន្តជំរុញ និង សហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការពិនិត្យសេក្តីព្រាងច្បាប់ស្តីពី " សៀគ្វីរួមបញ្ចូលគ្នា " ឱ្យបានសមស្របតាមស្តង់ដាអន្តរជាតិ ។

**ក៧**- បន្តរៀបចំប្រកាសក្រសួង ស្តីពី " ការណែនាំក្នុងការចុះបញ្ជីម៉ាក " ឱ្យបានក្នុងឆ្នាំ ២០០៩ ឬ ២០១០ ខាងមុខ ។

**ក៨**- បន្តរៀបចំប្រកាសក្រសួង ស្តីពី " ភ្នាក់ងារតំណាងចុះបញ្ជី និង ការពារម៉ាកនៅកម្ពុជា " ឱ្យបានក្នុងឆ្នាំ ២០០៩ ដើម្បីបង្រៀនដល់ភ្នាក់ងារតំណាងទាំងនោះឱ្យបានក្នុងឆ្នាំ ២០១០ ខាងមុខ ។

**ក៩-** បន្តសិក្សាស្រាវជ្រាវនីតិវិធីចុះបញ្ជី និង ការការពារម៉ាកល្បី និង រៀបចំប្រកាសក្រសួង អំពីការ អនុវត្តនីការចុះបញ្ជីម៉ាកល្បី ក្នុងដើមឆ្នាំ ២០០៩ ឬ ២០១០ ខាងមុខ ។

**ក១០-** បន្តសិក្សាស្រាវជ្រាវ ក្នុងការរៀបចំអនុក្រឹត្យ ស្តីពី " ការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា (Sub-Decree on Enforcement of IPRs)" ក្នុងគោលបំណងចាត់វិធានការណ៍ឱ្យមានប្រសិទ្ធិភាពជាងមុន ដោយកិច្ចសហការ រវាងអង្គភាពពាក់ព័ន្ធ ដូចជា តុលាការ ព្រះរាជអាជ្ញា ប៉ូលីសសេដ្ឋកិច្ច និងនាយកដ្ឋានទទួលបន្ទុកកម្មសិទ្ធិបញ្ញានានា ។

**ក១១-** សហការពិនិត្យច្បាប់ ប្រកាសនីយប័ត្រតក្កកម្ម ម៉ូដែលមានអត្ថប្រយោជន៍ និង គំនូរឧស្សាហកម្ម ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីអាចទាញយកអត្ថប្រយោជន៍ពីឋានៈប្រទេសក្រីក្រ (LDCs) នៃកម្ពុជា ក្នុងការធ្វើវិសោធនកម្មច្បាប់ខាងលើ និង.ឬ រៀបចំច្បាប់បន្ថែមថ្មីស្តីពី " ការផ្តល់អាជ្ញាប័ណ្ណបញ្ជាសំរាប់សុខភាពសាធារណៈ " ដែលជាអត្ថប្រយោជន៍ក្នុងការផលិតឱសថទូទៅ "អនេរិច ឱុរងស " នៅកម្ពុជា ក៏ដូចជា ការនាំចេញ-នាំចូល នូវប្រភេទឱថសខាងលើ ។

**ក១២-** ការសហការពិនិត្យផលចំនេញ និងប៉ះពាល់ ក្នុងការចូល ពិធិសាទីក្រុង ម៉ាដ្រីត. កិច្ចព្រមព្រៀងទីក្រុងម៉ាដ្រីត និង សន្ធិសញ្ញាស្តីពីម៉ាក របស់ប្រទេសសឹង្ហបុរី ។

**ក១៣-** សហការរៀបចំកម្មវិធីសិក្សាសំរាប់ថ្នាក់មហាវិទ្យាល័យ និងមហាជន

**ក១៤-** ពង្រឹងសមត្ថភាពមន្ត្រីការិយាល័យ និងនាយកដ្ឋាន ដើម្បីអាចធ្វើជាគ្រូបង្គោល វិស័យកម្មសិទ្ធិបញ្ញា ។

## ២-អភិក្រមគ្របដណ្តប់វិស័យកម្មសិទ្ធិបញ្ញា (Trade SWAP)

ដើម្បីពង្រឹងប្រព័ន្ធជាតិ អោយខ្លាំងបន្ថែមទៀតខាងកំណើតកម្មសិទ្ធិបញ្ញា ការការពារកម្មសិទ្ធិបញ្ញា រដ្ឋបាលកម្មសិទ្ធិបញ្ញា និងការអនុវត្តន៍កម្មសិទ្ធិបញ្ញាដើម្បីអោយស្របទៅនឹង ស្តង់ដាកម្មសិទ្ធិបញ្ញាអន្តរជាតិ និងដើម្បីគ្រាំទ្រទិសដៅអភិវឌ្ឍន៍ពាណិជ្ជកម្ម របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ការិយាល័យមានផែនការអនុវត្តគំរោងអាទិភាព នៃគំរោងសកម្មភាពកម្មសិទ្ធិបញ្ញាទាំង ៣៩ នៅឆ្នាំ ២០០៩-២០១០ ។

- បង្កើនល្បឿនក្នុងការពិនិត្យដោះស្រាយពាក្យបណ្តឹង ស្នើសុំទប់ស្កាត់ការរំលោភបំពានម៉ាក ក៏ដូចជាពាក្យបណ្តឹងលុបម៉ាក អោយបានឆាប់ជៀសវាងការកកស្ទះ ដែលជះឥទ្ធិពលមិនល្អដល់ការអនុវត្តន៍ច្បាប់ កម្មសិទ្ធិបញ្ញា នៅកម្ពុជា ។

- រក្សានិរន្តរភាពរៀបចំកត់ត្រា គ្រប់គ្រង និងចាត់ការពាក្យបណ្តឹងអោយមានលំហូរទៅតាមនីតិវិធី ដែលកំណត់ដោយច្បាប់ និង មានលក្ខណៈជាប្រព័ន្ធ ។

- បន្តតាមដានដាក់លក្ខខ័ណ្ឌដល់ការចុះបញ្ជីម៉ាក ដែលមានវិវាទ ក្នុងប្រព័ន្ធ IPAS ដើម្បីធានាដល់ប្រសិទ្ធភាពការងាររបស់ការិយាល័យចំណុះនាយកដ្ឋានកម្មសិទ្ធិបញ្ញា ។

- ក្រើនរំលឹកដល់មន្ត្រីអោយកែតំរូវផ្នត់គំនិតអសកម្ម ដោយប្រកាន់យកវប្បធម៌សហការការងារជាសារវន្ត ក្នុងការសិក្សាស្រាវជ្រាវបង្កើនការយល់ដឹងផ្នែកដោះស្រាយវិវាទកម្មសិទ្ធិបញ្ញាបរទេស មានដូចជា ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការវិធាននៃមជ្ឈត្តកម្ម និង សន្ធានកម្ម ដើម្បីពង្រីកសមត្ថភាពក្នុងការពិនិត្យ និង ដោះស្រាយពាក្យបណ្តឹងអោយកាន់តែមានប្រសិទ្ធភាព ។

- ប្រកាន់ខ្ជាប់វប្បធម៌ណែនាំ បញ្ចុះបញ្ចូលអោយអ្នករំលោភបំពានផ្នែកកម្មសិទ្ធិបញ្ញា ប្រែក្លាយខ្លួនអោយទៅជាម្ចាស់កម្មសិទ្ធិបញ្ញា ដែលជាកញ្ចប់ទុនជាតិមួយ ក្នុងការអភិវឌ្ឍនីសេដ្ឋកិច្ចជាតិ ។

-រៀបចំឯកសារទាក់ទងនឹងការងារវិវាទ ដើម្បីផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់សិស្ស និង សាធារណជន ។

## ខ-ការងារបច្ចេកទេសដែលទាក់ទង នឹងវិស័យកម្មសិទ្ធិបញ្ញា :

នាយកដ្ឋានមានគោលការណ៍ធ្វើឱ្យទំនើបឡើង នូវប្រព័ន្ធគ្រប់គ្រង និងចុះបញ្ជីពាណិជ្ជសញ្ញាដោយៈ

-បន្តបញ្ចូលទិន្នន័យម៉ាក ដែលបានចុះបញ្ជីហើយទៅក្នុង Computer Database តាមប្រព័ន្ធ IPAS

-ពង្រឹងដំណើរការត្រួតពិនិត្យម៉ាកដោយស្វ័យប្រវត្តិ តាមរយៈ Computer ចំពោះម៉ាកជារូបភាព ។

-បន្តរៀបចំកែលំអរប្រព័ន្ធចុះបញ្ជីម៉ាក តាមរយៈស្វ័យប្រវត្តិកម្ម (Computerization of Trademark Registration ) អោយកាន់តែមានប្រសិទ្ធិភាពខ្ពស់ និង សុក្រឹត្យ ។

-ជូនដំណឹងដល់អតិថិជន អោយមកចុះបញ្ជីម៉ាករបស់ខ្លួនសាជាថ្មី បន្ទាប់ពីបានចុះបញ្ជីរយពេល ១០ឆ្នាំ រួច ។

-រៀបចំឱ្យមានមជ្ឈមណ្ឌលពត៌មានកម្មសិទ្ធិបញ្ញាមួយ សំរាប់បំរើដល់អតិថិជនដែលមានបំណងចង់ស្វែងយល់ពីកម្មសិទ្ធិបញ្ញា និយាយរួម និង និយាយដោយឡែក ពីម៉ាកដែលបានចុះបញ្ជីរួចហើយ ឬ ឯកសារនានា ដែល ទាក់ទង និង ការចុះបញ្ជីម៉ាក និង វិវាទនានានៅកម្ពុជា ។

-រៀបចំយន្តការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់មហាជន និង អាជីវករ អំពីច្បាប់ដែល ទាក់ទង នឹងកម្មសិទ្ធិបញ្ញា ជាពិសេសច្បាប់ស្តីពីម៉ាកដើម្បីបង្កើនការយល់ដឹងរបស់ពួកគេ ។

-រៀបចំបោះពុម្ពផ្សាយ នូវព្រឹត្តិប័ត្រផ្លូវការអោយបាន ចំនួន ១២លេខ ក្នុងមួយឆ្នាំ ព្រមទាំងបញ្ចូលឯកសារទៅក្នុង CD ដើម្បីចែកជូនអតិថិជន ក្នុង និង ក្រៅប្រទេស ដែលបានចុះបញ្ជីការពារម៉ាករបស់ខ្លួននៅកម្ពុជា និង ខិតខំធ្វើព្រឹត្តិប័ត្រផ្លូវការជា CDs ។

-ពង្រឹងការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ដោយបង្កើនកិច្ចសហការអោយបានកាន់តែជិតស្និទ្ធិថែមទៀត ជាមួយស្ថាប័នមានសមត្ថកិច្ច ដើម្បីកាត់បន្ថយការរំលោភកម្មសិទ្ធិបញ្ញាអោយបានជាអតិបរមា ។

-បង្កើនសមត្ថភាពយល់ដឹងផ្នែកកម្មសិទ្ធិបញ្ញា កុំព្យូទ័រ និង ភាសាអង់គ្លេស ដល់មន្ត្រីជំនាញរបស់ នាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធតាមរយៈការបញ្ជូនទៅបណ្តុះបណ្តាលវគ្គហ្វឹកហ្វឺនក្នុង និង ក្រៅប្រទេស។

-បន្តរៀបចំគំរូពាក្យស្នើសុំ និង គំរូលិខិតស្នាមផ្សេងៗទៀត ជាភាសាខ្មែរ និង អង់គ្លេស ដើម្បីងាយស្រួលដល់ការអនុវត្តការងារចុះបញ្ជីម៉ាក ឱ្យបានកាន់តែប្រសើរឡើងថែមទៀត។

## គ-<u>ការងារគណៈកម្មការគ្រប់គ្រងវិស័យកម្មសិទ្ធិបញ្ញា</u> :

-រៀបចំវិសោធនកម្មសេចក្តីសំរេច ស្តីពីការបញ្ចូលបន្ថែមសមាជិកគណៈកម្មការការគ្រប់គ្រងវិស័យកម្មសិទ្ធិបញ្ញា ដែលមានសមាជិកមកពីបណ្តាក្រសួងពាក់ព័ន្ធទៅនឹងវិស័យកម្មសិទ្ធិបញ្ញា។

-ពិនិត្យមើលដំណើរការអនុវត្តន៍ ឱ្យមានភាពស៊ីសង្វាក់គ្នា និង ឯកភាពជាតិតែមួយក្នុងវិស័យកម្មសិទ្ធិបញ្ញា នៅកម្ពុជា និង ពង្រឹងកិច្ចសហការរវាងក្រសួងនានាដែល ពាក់ព័ន្ធនឹងការងារកម្មសិទ្ធិបញ្ញា ជំរុញការកសាងច្បាប់ទាំងឡាយនៃកម្មសិទ្ធិបញ្ញា ដាក់ជូនគណៈរដ្ឋមន្ត្រី និង រដ្ឋសភាអនុម័ត ឱ្យបានសមស្របនៃផលប្រយោជន៏កម្ពុជា និង បង្ហាញពីសុឆន្ទៈរបស់កម្ពុជា ក្នុងការកសាងច្បាប់ និង បទបញ្ញត្តិនានា ក្នុងនាមជាសមាជិកនៃអង្គការ WTO និង ដើម្បីអោយស្របទៅនឹងសភាពការណ៏វិវត្តន៍ជាក់ស្តែងនៃទីផ្សារកម្ពុជា និង ទាន់សភាពការណ៏វិវត្តន៍យ៉ាង ឆាប់រហ័សនៃវិស័យកម្មសិទ្ធិបញ្ញា នៅលើពិភពលោក។

-ពិនិត្យសិក្សាស្រាវជ្រាវ កិច្ចព្រមព្រៀង អនុសញ្ញាអន្តរជាតិ ពាក់ព័ន្ធ និង កម្មសិទ្ធិបញ្ញា ដើម្បីដឹងពីគុណ សម្បត្តិគុណវិបត្តិ ក្នុងការចូលជាសមាជិកនៃកិច្ចព្រមព្រៀង ឬ អនុសញ្ញាទាំងនោះ រួចរាយការណ៏ជូនថ្នាក់ដឹកនាំ ក្រសួង ដើម្បីពិនិត្យ និង សំរេច។

***ភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៨***

**ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា**